This project

co-is funded by:

Minute of Farmer Group 2 workshop from 26 – 27 April 2011

The workshop was participated by all model farmer group 2 and facilitated by core team member of CNFSC. The main objectives of the workshop are to 1)- Reflect what farmer group 2 have been done so far and 2)- Strengthen the agriculture their skills and knowledge for better implementation through doable plan.

# កំណត់ហេតុ

## ប្រជុំក្រុមកសិករគំរូក្រុមទី២(២៦-២៧ មេសា ២០១១ ស្រុកស្រែអំបិល)

## ស៊ឹម ហុន ២៦ មេសា ២០១១

ឆ្នាំពីរពាន់ដប់មួយ ខែមេសា ថ្ងៃទីម្ភៃប្រាំមួយវេលាម៉ោងប្រាំបីព្រឹកនៅការិយាល័យអង្គការម្លប់ព្រហ្មវិហារធម៌(MPC) ស្រុកស្រែអំបិល មានការប្រជុំឆ្លុះបញ្ចាំងមួយដោយផ្តោតលើលទ្ធផលកសិករគំរូក្រុមទី២ ក្រោមការសំរបសំរួលរបស់លោក ជឹម សុផល ប្រធានបណ្តាញសហគមន៍ដើម្បីអធិបតេយ្យភាពស្បៀងនៅកម្ពុជា ។

(សមាសភាពអ្នកចូលរួមមានភ្ជាប់ក្នុងតារាងវត្តមាន)

ជាកិច្ចចាប់ផ្តើមអ្នកស្រី ស៊ិន ស៊ីណនលេខាធិការបណ្តាញបានធ្វើការប្រកាសហេតុ និងណែនាំអោយស្គាល់គ្នាម្នាក់ម្តងគ្រប់សិក្ខាកាមដែលចូលរួមទាំងអស់ ដើម្បីងោយមានភាពស្និទិស្នាល និងដំណើរការប្រជុំបានរលូនរយៈពេលពីរថ្ងៃនៃកិច្ចប្រជុំឆ្លុះបញ្ចាំងនេះ ។

ជាបន្ទាប់គឺមតិសំណេះសំណាលរបស់លោក ម៉េង ហាក់វិឆ្ន័យៈនាយកអង្គការម្លប់ព្រហ្មវិហារធម៌ ដែលលោកសំដែងនូវការ ស្វាគមន៍យ៉ាងកក់ក្តៅ និងសប្បាយរីករាយដែលក្រុមកសិករគំរូបានមកប្រជុំគ្នានៅទីនេះ ។ ដូចដែលអស់លោកបានជ្រាបខ្លះហើយស្រុកស្រែអំបិលជាស្រុកមួយនៅក្នុងខេត្ត កោះកុង ហើយធ្លាប់លឺថាស្រុកនេះមានផលិតផលច្រើនលក់នៅទីផ្សារភ្នំពេញ តែពេលនេះយើងឃើញផ្ទាល់ថា ស្រុកនេះក៏ក្រីក្រណាស់ដែរ ។ក្នុងរយៈពេលពីរថ្ងៃនេះ សូមអោយអស់លោកយកចិត្តទុកដាក់ និងចែករំលែក ផ្តល់យោបល់អោយបានគ្រប់គ្នា ជាងនេះទៅទៀតយើងនឹងចុះទៅមើលដល់ផ្ទះកសិកររបស់អង្គការម្លប់ព្រហ្មវិហារធម៌នៅថ្ងៃទី២៧ មេសា ២០១១ ។ ចុងក្រោយនេះ ខ្ញុំសូមអោយការប្រជុំនេះប្រកបទៅដោយរលូន និងជោគជ័យ ។

ជាបន្តទៀតលោក ជឹម សុផលមានមតិបើកកម្មវិធីដូចតទៅៈ ជាដំបូងខ្ញុំសូមអរគុណចំពោះវត្តមានអស់លោក លោកស្រី ដែលអញ្ជើញចូលរួមការប្រជុំកសិករក្រុមទី២រយៈពេល២ថ្ងៃនេះ ។ ជាមួយគ្នានេះដែរ ខ្ញុំសង្ឃឹមថា យើងនឹងទទួលបានបទពិសោធន៍ ការចែករំលែកពីគ្នាទៅវិញទៅមក នឹងទទួលបានបញ្ហាប្លែកៗពីគ្នា ហើយយើងនឹងរកដំណោះស្រាយរួមគ្នា ធ្វើផែនការបន្តសំរាប់ អនុវត្តន៍បន្ត។ បន្ទាប់ទៅនេះ ខ្ញុំសូមប្រកាសបើកកម្មវិធីប្រជុំនេះពីពេលនេះតទៅ និងសូមអោយការប្រជុំ ទទួលបានជោគជ័យ ។

ក្រោយពីការបើកកម្មវិធី លោកយឹម ប៊ុនថេងបានបង្ហាញពីគោលបំណង និងលទ្ធផលរំពឹងទុកនៃកិច្ចប្រជុំដូចខាងក្រោមៈ

គោលបំណងៈ

១- ការឆ្លុះបញ្ចាំងពីលទ្ធផលការងារកសិករគំរូក្រុមទី២

២- ធ្វើផែនការសំរាប់កសិករគំរូក្រុមទី២អនុវត្តបន្ត

លទ្ធផលរំពឹងទុកៈ

- យល់ដឹងពីលទ្ធផលកសិកម្ម និងស្ថានភាពរបស់កសិករគំរូ និងរាល់បញ្ហានៃការអនុវត្តសកម្មភាពរបស់កសិករត្រូវបានអ្នកចូលរួមជួយដោះស្រាយប្រកបដោយភាពវិជ្ជមាន
- កសិករគំរូ នឹងទទួលបាននូវចំណេះដឹងថ្មីៗពីក្រុមកសិករដែលមកពីខេត្តផ្សេងៗ និងមានផែនការមួយច្បាស់លាស់របស់ខ្លួនដើម្បីយកទៅអនុវត្តនៅផ្ទះ ។

បន្ទាប់ពីការណែនាំ និងជ្រាបគោលបំណងប្រជុំហើយ អ្នកស្រី ស៊ិន ស៊ីណនបានសំរបសំរួលកសិករតាមខេត្តនីមួយៗ ដើម្បីធ្វើការបង្ហាញដល់ក្រុមដល់សិក្ខាកាមដែលចូលរួម និងជួយផ្តល់យោបល់កែលំអរបន្តទៀត ។

**ការបង្ហាញលទ្ធផលកសិករ**

របាយការណ៍លទ្ធផលរបស់កសិករគំរូ៤នាក់ ខេត្តពោធិសាត់ (វិច្ឆិកា ២០១០-មេសា ២០១១) RFCD

| ល.រ | សកម្មភាព | ចំនួន | ចំណូល | ចំណាយ | នៅសល់ |
|---|---|---|---|---|---|
| ១ | ត្រកួន | ៥រង | ៣២៣,៣០០ | ៧៤,៥០០ | ២៤៨,៨០០ |

| | | | | | |
|---|---|---|---|---|---|
| ២ | ដាំត្រសក់ | ៤៨រង | ២៥000 | 0 | ២៥000 |
| ៣ | ដាំស្ពៃក្រប់មុខ | ៧៩រង | ៧៣៨៤00 | ៤៦៦៦00 | ២៧១៨00 |
| ៤ | ដាំប៉េងប៉ោះ | ១៦រង | ៤២000 | ២000 | ៤0000 |
| ៥ | ដាំផ្ទីគ្រប់មុខ | ៦រង | ២៨000 | 0 | ២៨000 |
| ៦ | ដាំស្ពឺកខ្ទឹម | ២៧រង | ១៩១១00 | ៤៥៩00 | ១៤៥២00 |
| ៧ | ដាំននោង | ៦ទ្រើង | | | បានហូប |
| ៨ | ដាំជីគ្រប់មុខ | ២0រង | ៧២0000 | ៣000 | ៦៩000 |
| ៩ | សណ្តែកគួរ | ៤រង | ១0,000 | 0 | ១0,000 |
| ១0 | ត្រប់គ្រប់មុខ | ២៨រង | ១៣៨២00 | ៤៥00 | ១៣៣២00 |
| ១១ | ដាំម្រះ | ២រង | 0 | 0 | 0 |
| ១២ | ដាំម្ទូ | 0 | 0 | 0 | 0 |
| ១៣ | ដាំកញ្ចៃត | ២ស្រះ | | | |
| ១៤ | ដាំល្ហុង | ២៦ដើម | | | |
| ១៥ | ដាំចេក | ៧១ដើម | | | |
| ១៦ | ស្វាយ | ៧ដើម | | | |
| ១៧ | ស្ពឺកគ្រៃ | ១៨៣គុម្ព | ១0៩,000 | 0 | ១0៩000 |
| ១៨ | រមៀត | ២រង | 0 | 0 | 0 |

| | | | | | |
|---|---|---|---|---|---|
| ១៩ | ដមឡូងគ្រប់មុខ | ៣៩គុម្ព | | | |
| ២០ | ម្ទេស | ៩រង | | | |
| ២១ | ខ្ញី | ២រង | | | |
| ២២ | រំដេង | ៤គុម្ព | | | |
| ២៣ | ពោត | ១៤រង | 0 | ៩៥00 | ៩៥00 |
| ២៤ | ខាតណា | ៩រង | ៦៧៤00 | ៤000 | ៦៣៤000 |
| ២៥ | ឆៃថាវ | ១៦រង | ៤៣១00 | ៥000 | ៣៨១00 |
| ២៦ | ស្រូវប្រាំង | ៥0អា | ១៦៩៨ គ.ក | ២១៤៨00 | ១១៣៤000 |
| ២៧ | ចិញ្ចឹមមាន់ | ២៩៧ក្បាល | ៤៨៨00 | ១៩២000 | ៩៦២000 |
| ២៨ | ចិញ្ចឹមទា | ២ក្បាល | ១១៥៤0៦00 | 0 | 0 |

**ចំណាយថវិកាបន្ថែលនៅសល់**

- ទិញក្របី១ក្បាល ១,៩00,000៛
- ទិញអាគុយប្រើប្រាស់ក្នុងផ្ទះ ១៣៦,000៛
- ទិញម្ហូបអាហារគ្រឿងទេស កូនរៀន បុណ្យ ការ

**បញ្ហាជួបប្រទះ**

- ធ្វើជីអ៊ីអឹម ជូ - ដាក់ជីកំប៉ុសច្រើនស្រូវងាប់ -ដង្កូវស៊ីរូងដើម-ជីមានមេរោគ-អាសន្នរោគមាន់ -ដួងល្ហោចស្លឹក និងបណ្តូល

-ដួងស៊ីគល់ចេក -ដាំពិសោធន៍ខ្ទឹមសបរាជ័យ

# លទ្ធផលការងារកសិករគំរូ អង្គការសាមគ្គី ខេត្តកំពង់ចាម

- ការចិញ្ចឹមមាន់: មេ=៣៨ក្បាល : ចំណូលសរុប: ២,៣១០,៥០០៛ ចំណាយសរុប: ១,០៤៤,០០០៛

- ចិញ្ចឹមទា មេ=១៧ក្បាល : ចំណូលសរុប: ៤០០,០០០៛ លក់ពងទា: ៥០,០០០៛ ចំណាយសរុប: ១៤៥,០០០៛

- ចិញ្ចឹមជន្លេន ៤អាង :ចំណូល ៦០,០០០៛ ចំណាយ ៤៨,០០០៛ ( ទិញអាង)

- ស្ពៃចង្កឹះ ១០រង : ចំណូល ៣៧៦,០០០៛ ចំណាយ ៦,៦០០៛

- ដាំត្រកួន: ១៦រង: ចំណូល ១៨០,០០០៛ ចំណាយ ៤៦,៥០០៛

- សណ្តែកគួរ : ចំណូល ២០,០០០៛ ចំណាយ ៤,០០០៛

- ដាំខ្ទឹមស្លឹក ៣រង : ចំណាយ ៣៧,០០០៛ ចំណូល......( មិនទាន់លក់, ថោកពេក)

- ជីគ្រប់មុខ ៤០រង : ចំណាយ ៥,០០០៛ ចំណូល ( មិនទាន់លក់...)

- ស្លឹកគ្រៃ ៧រង : ចំណាយ ២០,០០០៛ ចំណូល ៣៦,០០០៛

- ននោង និងត្រឡាច ២៥គុម្ព ចំណាយ ...0. ចំណូល...0..មិនទាន់លក់

- ត្រសក់ ៣រង : ចំណាយ ២០,០០០៛ ចំណូល ៥០,០០០៛

- ម្រះព្រៅ ៣រង : ចំណាយ ....0 ចំណូល ៥,០០០៛

- ម្រះ : ចំណាយ ២,៥០០៛ ចំណូល ២០,០០០៛

- ផ្សិតចំបើង ៥រង : ចំណាយ ៦០,០០០៛ ចំណូល ២៥០,០០០៛

- ប្រជុំឆ្លុះបញ្ចាំង និងផ្សព្វផ្សាយពីការចិញ្ចឹមមាន់ដល់សមាជិកពង្រីក ចំនួន៤លើកមានអ្នកចូលរួមចំនួន៧៦នាក់ប្រុស២០នាក់។ ប្រធានបទការរៀបចំទ្រុង ការថែទាំ និងការធ្វើវ៉ាក់សាំងធម្មជាតិការពារជំងឺមាន់។

- ប្រជុំសមាជិកក្រុមប្រចាំខែចំនួន១១លើកមានអ្នកចូលរួមសរុប៦៤នាក់ប្រុស៨នាក់ ។

- តាមដាន និងផ្តល់យោបល់តាមផ្ទះចំនួន២០ដង ។

## បញ្ហាជួបប្រទះ

- បន្លែចៃសរុំផ្លែ( ល្ហុង, សណ្តែកគួរ, ត្រប់...) - ដង្កូវស៊ីស្លឹក( ស្ពៃ សណ្តែកគួរ - ជម្ងឺមាន់: រាក, ពកភ្នែក, ស្លាប់ភ្លាម ។ អាកាសធាតុក្តៅ ខ្វះទឹកស្រោចស្រព ។

ក្នុងនេះដែរ អ្នកស្រី សូ អានបាននាំមកជាមួយនូវសត្វខ្មុង ដែលជាសត្រូវរបស់កសិករដើម្បីបង្ហាញពីបញ្ហា និងសូមអោយក្រុមធំជួយរកដំណោះស្រាយ ។ នេះឳកាសល្អសំរាប់បង្ហាញ និងពិសោធន៏អោយសិក្ខាកាមមើលផ្ទាល់ដោយប្រើសាធាតផ្សំ: អំបិល សាប៊ូ លាយទឹករួចបាញ់ទៅលើសត្វ ។វិធីនេះឃើញថាមានប្រសិទ្ធិភាពធ្វើអោយសត្វនេះស្លាប់ក្នុងរយ:ពេល១៥នាទី ។ នេះជាមេរៀន និងសំរាប់កសិករផ្សេងយកទៅអនុវត្តន៏នៅមូលដ្ឋានរបស់ខ្លួនរៀងខ្លួន១ ។

## ផែនការបន្ត

- រៀបចំស្រែចំការរដូវវស្សា( រៀបចំថ្នាល សាបស្រូវ )
- ដាំពោត ដាំសណ្តែកបាយ និងសណ្តែកសៀង -ធ្វើជីកំប៉ុស-ដាំបន្លែចំរុះ-ចាប់ផ្តើមចិញ្ចឹមសត្វបន្ត និងពង្រីកបន្ថែម
- បន្តផ្សព្វផ្សាយពីការធ្វើជីធម្មជាតិ( អ៊ុអឹម...) - តាមដានសកម្មភាពសមាជិកពង្រីកបន្ត - ជួសជុលស្រះទឹក

**របាយការណ៍កសិករគំរូនៅខេត្តស្វាយរៀង អង្គការ** ADIFE

១- ពោជ សារិន:

- ផ្លៃលក់បាន ១០,៥០០៛-ត្រកួនលក់បាន ៣០,០០០៛-ខ្ទឹមស្លឹកលក់បាន ៤៨,៥០០៛-មាន់លក់បាន ៥២០,០០០៛( ៤០គ.ក/១៣,០០០៛)
- ទាលក់បាន ២៨៤០០០៛( ៣៣គ.ក/៨០០០៛) -ត្រីស្រែ ២៥គ.ក/៩០០០៛=២២៥,០០០៛-ត្រីឆ្តិន ២០គ.ក/៦០០០ =១២០,០០០៛ -ត្រីប្រា ៤០គ.ក/៦០០០=២៤០,០០០៛ សរុប= ១,៤៧៨,០០០៛- ជីកស្រះថ្មីបានចំនួន០៧ស្រះ ( ជួយដោយ អង្គការហ្វាវ)

២- សៅ ព្រីង ភូមិថ្មី ឃុំចំបក់ ស្រុកស្វាយជ្រុំ ស្វាយរៀងខែមករា-ខែមិនា)

- ត្រសក់ ១០០គ.ក= ១៥០,០០០៛ -ត្រកួន = ១០០,០០០៛ -ខ្ទឹមស្លឹក ១០០គ.ក= ៣០០,០០០៛ ម្រះ ៣០គ.ក= ៦០,០០០៛

- មាន់ ១០គ.ក = ១២០,០០០៛ -ស្លឹកគ្រៃ = ១៥គ.ក= ១៥,០០០៛ -ជ្រក់មមាញ់= ២០,០០០៛ -សរុប= ៦៥៧,០០០៛

៣- លោក អ៊ាង ឈាន

- ស្ពៃ ៩រង ១៨០គ.ក/១៥០០= ២៧០,០០០៛ -ត្រកួនគោកលក់១៦០,០០០៛ ចិញ្ចឹមជ្រក់មេកើតបានកូន ០៥ក្បាលកូន១ក្បាល លក់បាន១៥០,០០០៛=៥ក្បាល=៧៥០,០០០៛ -មាន់ មេមាន់ ២ក្បាលមានកូន១៥ក្បាល -យកប្រាក់លក់កូនទៅទិញបាន កូនគោចំនួន២ក្បាលទុកសំរាប់ចិញ្ចឹមបន្ត

៤- ពៅ ស៊ីន

- ត្រកួន ២រង -ខ្ទឹមស្លឹក១រង -ត្រសក់៤រង -ត្រកៀត ១គ្រែង -សរុបប្រាក់ចំណូល៤៦,០០០៛ -ជ្រូកមេ ២ក្បាលបានកូនចំនួន៩
- ជ្រូកសាច់២ក្បាល -លក់ជ្រូកសាច់១ក្បាល=៣៧៤,០០០៛ -មាន់សរុប ៣៨ក្បាល-មាន់មេ៤ក្បាល, ឈ្មោល២ក្បាល
- កូនមាន់៨ក្បាល

**បញ្ហាជួបប្រទះសំរាប់ខេត្តស្វាយរៀង**

- អាសន្នរោគមាន់ (ញូវកាស)-ខ្វះទឹកស្រោចស្រពលើដំណាំ-សត្វទិចផ្លែម្រះ -ជម្ងឺកើតគោ ក្របី (អុតក្តាម, សារទឹក)សត្វល្អិត បំផ្លាញដំណាំត្រឡាច ល្ពៅ ននោង ។

**លទ្ធផលការងារកសិកររបស់អង្គការម្លប់ព្រហ្មវិហារធម៌**

១- អ្នកស្រី យិន សាម៉ាក់

| ល.រ | ឈ្មោះដំណាំ | ចំនួន | ចំណូល | ចំណាយ |
|---|---|---|---|---|
| ១ | ស្លឹកគ្រៃ | ៩គុម្ព | ២០,០០០រៀល | គ្មាន |
| ២ | ឪឡឹក | ៣រង | ៨៦,៧០០រៀល | គ្រាប់ = ៧,០០០រៀល |
| ៣ | ដំឡូងឈើ | ២រង | ១០៥,០០០រៀល | ដើម=៩,០០០រៀល |
| ៤ | ផ្លែទឹកដោះគោ | ២៤ដើម | ២,៦៥០,០០០រៀល | ជីកជញ្ជូន =១,២៤៨,០០០រៀល |

| | | | | |
|---|---|---|---|---|
| ៥ | មាន់ | ២០ក្បាល | ៦០៨,000រៀល | កន្ទួក ស្រូវ ជីកជញ្ជូន ១០៣,៧០០៛ |
| ៦ | ជ្រូក | ៧ក្បាល | ៤,០៨០,000រៀល | ៥៥០,000រៀល |
| ៧ | ត្រកួន | ៥រង | ១០៨,000រៀល | គ្រាប់=៣0000រៀល |
| ៨ | គ្រាប់ស្វាយចាន់ទី | ២៥គ | ១២៥,000រៀល | គ្មាន |
| សរុបប្រាក់ចំណេញក្រោយពេលដកចំណាយ | | | ៥,៨៣៥,000រៀល | |

២- លោក ជា សំណាង

| ល.រ | ឈ្មោះដំណាំ | ចំនួន | ចំណូល | ចំណាយ |
|---|---|---|---|---|
| ១ | ត្រកួន | ៨រង | ១៣៦,000រៀល | ២៤,000រៀល |
| ២ | ស្ពៃក្រញាញ់ | ១៤រង | ៤២០,000រៀល | ២១,000រៀល |
| ៣ | ស្ពៃចង្កឹះ | ៦រង | ១១៤,000រៀល | ៩,000រៀល |
| ៤ | ស្ពៃជើងទា | ៤រង | ៩២,000រៀល | ៤,000រៀល |
| ៥ | ឆៃថាវ | ២រង | ១៤,000រៀល | ២,000រៀល |
| ៦ | ធ្មី | ១៦រង | ១២៣,000រៀល | គ្មាន |
| ៧ | ចេកអំបូង | ៣ស្ទង | ៦០,000រៀល | គ្មាន |
| ៨ | មាន់ | ១០ក្បាល | ១៨០,000រៀល | ១៨,000រៀល |
| ៩ | ទាកាប៉ា | ៥ក្បាល | ២00,000រៀល | ៤0,000រៀល |
| សរុបចំណូលពេលដក់ចំណាយរួច | | | ១,២២១,000រៀល | |

៣-អ្នកស្រី សៀង ផេន

| ល.រ | ឈ្មោះដំណាំ | ចំនួន | ចំណូល | ចំណាយ |
|---|---|---|---|---|
| ១ | ត្រកួន | ៦រង | ៣៥0,000រៀល | ២0,000រៀល |
| ២ | សណ្តែកគួ | ៥រង | ២៥0,000រៀល | ១៥,000រៀល |

| | | | | |
|---|---|---|---|---|
| ៣ | ប៉េងប៉ោះ | ៣៥គុម្ព | ១៦០,០០០រៀល | ៣,០០០រៀល |
| ៤ | ម្ទេស ស្លឹកគ្រៃ | ៦០គុម្ព | ១៥០,០០០រៀល | គ្មាន |
| ៥ | ស្ពៃមើម | ៥រង | ៣០០,០០០រៀល | ១២,០០០រៀល |
| ៦ | ស្ពៃចង្កឹះ | ២រង | ៨០,០០០រៀល | ២,០០០រៀល |
| ៧ | កញ្ឆែត | ១ស្រះ | ៥០,០០០រៀល | ២,០០០រៀល |
| ៨ | ល្ពៅ | ៣៥គុម្ព | ១០០,០០០រៀល | ១,៥០០រៀល |
| ៩ | ត្រប់ | ៣០គុម្ព | ១៥០,០០០រៀល | ១,៥០០រៀល |
| ១០ | ផ្ទី | ៥រង | ១៥០,០០០រេ០ល | ១,៥០០រៀល |
| សរុបប្រាក់ចំណេញក្រោយពេលដក់ចំណាយ | | | ១,៦៨៣,៥០០រៀល | |

**បញ្ហាជួបប្រទះរួមមានៈ**

កណ្ដៀវ ស៊ីផ្លែ និងគល់ដំណាំ មាន់ឈឺ និងងាប់ បន្លែដាំច្រើនពិបាករកទីផ្សារ ខ្វះទឹក និង តំបន់មានទឹកនៅឆ្ងាយ ស្រមោចស៊ីគ្រាប់ពូជដែលបណ្ដុះ ដង្កូវស៊ីស្លឹកស្ពៃ មាន់ងាប់ច្រើន ចៃស៊ី រលួយគល់ ដង្កូវរុំស្លឹក អណ្ដើកមាស មាន់បាត់គ្មានមូលហេតុ ដំណាំច្រើនពិបាកលក់។

**ដំណោះស្រាយដែលកសិករបានដោះស្រាយមានៈ**

ពេលមាន់ឈឺយកមាន់ឈឺនោះដាក់ឱ្យឆ្ងាយពីពីមាន់ដ៏ទៃ សំអាតទ្រុង ស្នូកចំណី ស្នូកទឹក និងបរិវេនជុំវិញទ្រុង ជាប្រចាំ។ ជំរះស្មៅ ដាក់ជីបន្ថែម បាញ់ថ្នាំបណ្ដេញសត្វល្អិត -បន្លែយកដើលក់តាមតាមផ្ទះក្នុងភូមិ ។ -ធ្វើកំប៉ុស្ដិ៍គោគបន្ថែម ។ -ពង្រឹងការចិញ្ចឹមមាន់ - ទិញជ្រូកចិញ្ចឹមបន្ត - ដាំសណ្ដែកគួរ ម្រះ ននោង ត្រកួន ត្រឡាច -ពេលដង្កូវស៊ីស្លឹកបាញ់ថ្នាំបណ្ដេញសត្វល្អិត-ធ្វើផ្ទៃសំរាប់បណ្ដុះគ្រាប់ពូជកុំឱ្យស្រមោចស៊ី ជើងរានត្រូវរុំក្រណាតជ្រលក់ប្រេងម៉ានស៊ីន -ពេលមានអ្នកជិតខាងងាប់ចាប់មាន់ក្រុង និងបន្តក់វ៉ាក់សាំងធម្មជាតិ -បាញ់ថ្នាំបណ្ដេញសត្វល្អិត -កាច់មែកដែលដង្កូវរុំចោល -មាន់ចាប់ក្រុង និងដាក់ក្នុងទ្រុង ។

បន្ទាប់ពីស្ដាប់ការរាយការណ៍របស់កសិករគំរូទាំង៤ខេត្ត ឃើញថាបញ្ហា និងដំណោះស្រាយប្រហាក់ប្រហែលគ្នា ។ ក្នុងនោះលោក អួត ឡុងបានចែករំលែកពីចំណេះដឹង និងបទពិសោធន៍ដែលធ្លាប់អនុវត្តន៍កន្លងមក ដើម្បីជាទុនសំរាប់សិក្ខាកាមយកទៅសាកល្បង និងបន្តផ្សព្វផ្សាយដល់កសិករពង្រីកនៅមូលដ្ឋានរបស់ខ្លួនតាមខេត្តរៀងខ្លួន ដែលចំណេះដឹងទាំងអស់នោះលោក អួត ឡុងធ្លាប់បានចងក្រងជាសៀវ

ភៅចែកជូនតាមខេត្តរួចហើយ សូមពិនិត្យមើល អនុវត្តន៍សាកល្បង និងកែច្នៃបន្ថែម ។ ខាងក្រោមនេះជាការសង្ខេបពីបញ្ហា និងដំណោះស្រាយមួយចំនួនសំរាប់កសិករ និងត្រូវមើលសៀវភៅបន្ថែម ដែលសំខាន់នោះគឺត្រូវពឹងលើទឹកចិត្តឆន្ទះ ជី និងពូជផងដែរ ។

ផ្សេងៗពីស្ដី: ថ្នាំបន្តក់មាន់(វ៉ាក់សាំងធម្មជាតិ) ថ្នាំពុលធម្មជាតិជីធម្មជាតិ ពូជដំណាំ ចំណូល

- អ៊ី អឹមជូ: ត្រូវធ្វើកិរិតនៃបច្ចេកទេស ចំណែកដីមានមេរោគ ត្រូវប្រើមេជីអ៊ី អឹម ។ ដើម្បីការពារសត្វល្អិតត្រូវប្រើអង្កាមដុតបាចលើដី ឯដូងស៊ីគល់ចេក: ប្រើផេះជាជី និងបណ្ដេញមេរោគ ។

- មេរោគ, ព្រូន, មាន់ងាប់: ត្រូវមានវិធានការការពារជាមុនឆ្លងព្រូន, កុនមាន់កុំអោយប៉ះដី ប្រើក្រដាស,ឬក្រណាតទ្រាប់រយៈពេលមួយអាទិត្យត្រូវប្រើធ្យូង ឬអង្កាមដុតកំដៅរយៈពេលមួយអាទិត្យ បន្ទាប់មកប្រើចំណី: ស្រូវត្រូវត្រាំ ស្ងោ ហើយដាក់គល់ស្លឹកគ្រៃ ឬស្លឹកខ្ទឹម ។ ទ្រុងមាន់ត្រូវទុកដោយឡែក ហាមមិនអោយមនុស្ស ឬសត្វផ្សេងចូលព្រោះនាំអោយឆ្លងមេរោគពីខាងក្រៅ ។ ចំណែកអុតមាន់: ត្រូវបេះដោយដៃ, ប្រើទឹកអ៊ីអឹម ទឹកអាល់កុល ទឹកក្រូចឆ្មាជូតវាអោយជ្រះ ។មាន់ងាប់ចោលពងៈ យកស្រូវលីងឬហាលរួចក្រាលពីលើពីក្រោម(ហាលស្រូវជាពីរបំណែកដើម្បីផ្លាស់ប្ដូរយប់ថ្ងៃ) ។ ពិសោធន៍សត្វល្អិតបំផ្លាញដំណាំ: មានទកខ្ទេះម្ទេស សាប៊ូអំបិល ឬពិសបន្សាបពិស និងក្លិនរុក្ខជាតិណាដែលមានជាតិកំពុលខ្លាំង ។ ចំណែក រលួយគល់ដំណាំបន្លែ: ត្រូវពិនិត្យលើដីលើដំណាំ,ការប្រើប្រាស់ជី,និងការស្រោចទឹក ។

ក្រោយពីលោក អូត ឡុងចែករំលែក អ្នកស្រី ស៊ិន ស៊ីណនបានបង្ហាញលើតារាងចំណាយ ចំណូល(ទិន្នន័យវិភាគតាមសាម៉ីអង្គការ)

ដែលមានការជជែកគ្នា: ដើម្បីសំរេចអោយកសិករងាយស្រួលក្នុងការតាមដានពីស្ថានភាព រីកចំរើន ឬការអន់ថយផ្សេងៗសំរាប់ប្រៀបធៀបចុងគ្រា និងដើមគ្រានៃការអនុវត្តកសិកម្មរបស់ខ្លួន ។

<u>តារាងទិន្នន័យ(វិភាគតាមសាម៉ីអង្គការ)</u>

រយៈពេល........................................(ចាប់ពីខែ...........ដល់ខែ..........ឆ្នាំ២០........)

| ល.រ | ឈ្មោះដំណាំ | ឯកតា | ចំនួន | តំលៃរាយ | តំលៃសរុប | ចំណាយ | ថវិកានៅសល់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| រដូវវស្សា | | | | | | | | |
| ១ | ត្រកួន | ៥រង | ១០០ដុំ | ៥០០៛ | ៥០,០០០៛ | ១០,០០០៛ | ៤០,០០០៛ | ហូបក្នុងគ្រួសារ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២ | សណ្តែកគួ | ១០រង | ១០០គ.ក | ២០០៛ | ២០,០០០៛ | ៥,០០០៛ | ១៥,០០០៛ | |
| ៣ | | | | | | | | |
| រដូវប្រាំង | | | | | | | | |
| ១ | ដំឡូមី | ៥រង | ១០០ដុំ | ៥០០៛ | ៥០,០០០៛ | ១០,០០០៛ | ៤០,០០០៛ | |
| ២ | ស្ពៃក្រញាញ់ | ១០រង | ១០០គ.ក | ២០០៛ | ២០,០០០៛ | ៥,០០០៛ | ១៥,០០០៛ | |
| ៣ | | | | | | | | |
| ៤ | | | | | | | | |
| សរុបទាំងអស់ | | | | | ១៤០,០០០៛ | ៣០,០០០៛ | ១១០,០០០៛ | |

មតិបូកសរុបការបង្ហាញរយៈពេល១ថ្ងៃរបស់កសិករទាំង៤ខេត្តដោយ លោក យឹម ប៊ុនថេង:

១- ចំពោះការវិភាគចំណូលចំណាយសូមអោយមានភាពច្បាស់លាស់ទើបយើងអាចធ្វើការប្រៀបទៅនិងទិន្នន័យឆ្នាំចាស់បាន ដោយមានតារាងចំណូល ចំណាយអោយបានត្រឹមត្រូវ

២- បញ្ហាជួបប្រទះ សូមអោយមានការដោះស្រាយអោយអស់លទ្ធភាព សឹមយើងរកជំនួយ ហើយសូមអោយមានការចងក្រងតាមដានជាឯសារ ដើម្បីរៀនសូត្រ និងចែករំលែកដល់សមាជិកយើងផងដែរ ។

៣- ក្នុងនាមយើងជាកសិករគំរូ ធ្វើយ៉ាងណាអោយគេមានការជឿជាក់ ធ្វើយ៉ាងណាអោយក្លាយជាគំរូគេពិតប្រាកដ នោះគឺត្រូវមានឆន្ទះជាត្រីមុខ ទើបគេអាចយកជាគំរូបាន ។

៤- ដើម្បីឆ្លើយតបនិងបញ្ហាដំណាំត្រូវផ្អែកលើចំណុច៤គឺ:

- មេកានិច គឺប្រើកំលាំង ឧទាហរណ៍ ត្រូវចាប់សត្វល្អិតដោយដៃ
- ជីវសាស្ត្រ គឺប្រើប្រាស់សត្វមានប្រយោជន៍ និង ឥតប្រយោជន៍
- វិធានការចំរុះ គឺដាំដំណាំចំរុះ

- គីមី( ថ្នាំពុល ធម្មជាតិ និងគីមី)

**ថ្ងៃ ទីបហេន ( ២៧ ខែមេសា ឆ្នាំ២០១១)**

ចុះទស្សនៈកិច្ចសិក្សានៅផ្ទះកសិករគំរូ របស់អង្គការ MPC :

១- អ្នកមីង **យិន សាម៉ាក់** នៅភូមិ បឹងព្រាវ ឃុំ បឹងព្រាវ

- ចំនុចល្អ: ដាំដំណាំជីវសាស្ត្រ ដាំបន្លែឆ្លាស់តាមរដូវកាល មានប្រភពទឹកគ្រប់គ្រាន់ ធ្វើបានច្រើនលើសពីផែនការ សួនមានលក្ខណៈជាកសិដ្ឋានមានការប្រើប្រាស់ជីធម្មជាតិមានការ ទំនាក់ទំនងល្អជាមួយក្រុមពង្រីក មានចិញ្ចឹមសត្វមាន់ និងជ្រូកដោយជ្រើសរើសពូជបានល្អមានឆន្ទៈ និងយកចិត្តទុកដាក់លើការងារ...។
- ចំនុចខ្វះខាត: មិនទាន់មានការសហការគ្នាលើការលក់បន្លែនៅលើទីផ្សារ ការធ្វើជីមិនបានជាប់រហូត សំរាប់ប្រើប្រាស់។
- អនុសាសន៏: គួរតែពិភាក្សាជាមួយក្រុមពង្រីកមុននឹងយកផ្លែឈើ ឬបន្លែទៅលក់នៅលើទីផ្សារ គួរតែធ្វើជីឱ្យបានជាប់រហូតសំរាប់ប្រើប្រាស់។

២- លោកពូ **ជា សំណាង** នៅភូមិជ្រោយ ឃុំបឹងព្រាវ

- ចំនុចល្អ: មានដីតូចតែប្រើអស់លទ្ធភាពពេញមួយឆ្នាំ ដាំបន្លែចំរុះ មានការធ្វើជីធម្មជាតិសំរាប់ប្រើ ប្រាស់ បណ្តុះគ្រាប់ពូជមុនពេលដាំ ធ្វើថ្នាលបណ្តុះពូជបានល្អការពារស្រមោច ដាំសាលាដបានល្អ ចេះគ្របចំបើង និងស្បៃការពារកំដៅថ្ងៃ និងការពារភ្លៀងធ្លាក់ (នៅរដូវភ្លៀងគាត់ដាំស្ពៃបានល្អ ជាងគេទាំងដែលគេដាំមិនកើត)។
- ចំនុចខ្វះខាត:មិនសូវដាំដំណាំជីវសាស្ត្រការដាំផ្ទីមិនមានរបៀបមិនមានរងពាសវាលពាសកាល ការដាំម្រះធ្វើទ្រើងមិនទាន់ពេលម្រះធំ ហើយមិនបានរុំផ្លែម្រះធ្វើឱ្យសត្វបំផ្លាញអស់។
- អនុសាសន៏: គួរតែនាំគ្នាធ្វើឱ្យបានច្រើនសំរាប់ប្រើប្រាស់ ធ្វើទ្រើង និងរុំម្រះឱ្យបានទាន់ពេលវេលា ។

៣- លោកពូ **ស ខន** នៅភូមិជ្រោយស្វាយកើត ឃុំជ្រោយស្វាយ

- ចំនុចល្អ: ទើបតែចូលជាកសិករគំរូថ្ងៃទី០៣-០៣-២០១១ តែអនុវត្តបានល្អ ដាំបន្លែបានជាង ២០មុខ មានស្រះចិញ្ចឹមត្រីមានឆន្ទៈ ពង្រីកក្រុមបានចំនួន ៥នាក់ទៀត។
- ចំនុចខ្វះខាត: មិនទាន់មាន។

- អនុសាសន៍:គួរតែយកមេរៀនពីកសិករគំរូរមុនហើយមកអនុវត្តបន្ថែមឱ្យបានច្រើនជាងនេះ ដើម្បីធ្វើការចែករំលែកបន្តដល់សមាជិកពង្រីក។

៤- អ្នកមីង **សៀវ ផេន** នៅភូមិសារាយ ឃុំជ្រោយស្វាយ

- ចំនុចល្អ: ផ្លាស់ប្តូរទ្រុងមាន់ទៅតាមការផ្តល់យោបល់របស់ក្រុមតាមដាន រៀបចំការចិញ្ចឹមមាន់បាន ល្អ មានអនាម័យ ។
- ចំនុចខ្វះខាត: មិនទាន់គ្រប់គ្រងកាកសំណល់នៅក្បែផ្ទះសំរាប់ធ្វើជីឱ្យបានល្អ ប្រើប្រាស់ដីមិនទាន់អស់ ដីនៅទំនេរច្រើន មិនទាន់ចេះកែច្នៃធនធានដែលមានស្រាប់ដើម្បីលក់។
- អនុសាសន៍: បង្កើនការដាំបន្ថែមទៀត និងប្រមូលសំរាមនៅក្នុងភូមិទុកឱ្យបានល្អសំរាប់ធ្វើជី។

មតិបន្ថែមរបស់លោក **យឹម ប៊ុនថេង** នាយកអង្គការ COFAP ខេត្តព្រៃវែង ចំពោះសួនរបស់អ្នកមីង **យិន សាម៉ាក់** មានប្រភពទឹកគ្រប់គ្រាន់ល្អហើយ ហើយយើងឃើញថាគាត់ចំណាយលើប្រេងក្នុងការ មូបទឹកយកមកស្រោច ប្រសិនបើអាចអ្នកមីងគួរតែរៀបចំជាអាងស្តុបទឹកមួយហើយនៅពេល ស្រោច ដំណាំគ្រាន់តែបើចេញពីអាងនោះដោយមិនចាំបាច់ចំណាយប្រេងទៀតឡើយ ព្រោះដីមីង មានលក្ខណៈជំរាលជើងភ្នំ។

មតិបិទកម្មវិធី របស់លោក **ជឹម សុផល** ប្រធានបណ្តាញ ជណាធ្យេច :សូមអរគុណចំពោះការយកចិត្តទុកដាក់របស់អ្នកទាំងអស់គ្នាសារជាថ្មី តាមរយៈការប្រជុំរយៈពេល ២ថ្ងៃកន្លងមកនេះឃើញថាក្រុម កសិករក្រុមទី២ នេះទទួលលទ្ធផលកើនឡើងបើធៀបនឹងក្រុមទី១ ហើយក្រុមយើងទើបតែកើត ឡើងនៅពាក់កណ្តាលឆ្នាំ ២០១០ នោះទេ។ រហូតមកដល់ពេលនេះក្រុមយើងចេះគ្រប់គ្រងពូជ ចេះវេចខ្ចប់បានត្រឹមត្រូវ ទុកដាក់បានត្រឹមត្រូវ ហើយបានយកមកចែករំលែកគ្នានៅក្នុងការប្រជុំនេះ ចេះពីបច្ចេកទេសក្នុងការដាំ ការធ្វើជី ការចិញ្ចឹមសត្វ បានច្រើនគួរឱ្យកត់សំគាល់ មិនត្រឹមតែប៉ុណ្ណោះទេ ប្រាក់ចំណូលក៏មានការកើនឡើងទៀត។ ទាំងនេះសុទ្ធសឹងតែជាការខិតខំប្រឹងប្រែងរបស់បងប្អូនទាំងអស់គ្នា។ហើយចុងក្រោយខ្ញុំសង្ឃឹមថាបងប្អូន នឹងបន្តការងារនេះជារៀងរហូតហើយសូមជូនពរឱ្យអ្នកទាំងអស់គ្នាជួបតែសេចក្តីសុខ និងជោគជ័យរាល់ការងារកសិកម្ម។ សូមអរគុណ។

ការប្រជុំនេះចប់នៅវេលាម៉ោង ៤:៣០ នាទីល្ងាច ដោយភាពរីករាយ ។

ធ្វើនៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១១

អ្នកធ្វើកំណត់ហេតុ

